**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ លើកទី៣
## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០

*សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!*
*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី!*
*សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក្មួយៗ សិស្សានុសិស្ស និស្សិត មាតាបិតា អាណាព្យាបាល និងបងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់រាប់អាន!*

ក្នុងនាមរាជរដ្ឋាភិបាល ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការចូលរួមអបអរសាទរជាមួយសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត មាតាបិតា អាណាព្យាបាល និងបងប្អូនជនរួមជាតិទាំងអស់ ក្នុងឱកាសដ៏មហោឡារិកនៃការប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ក្រោមប្រធានបទ **"TVET ធ្វើឱ្យជីវិតកាន់តែប្រសើរ"**។ ក្នុងស្មារតីបន្តអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ដ៏កាចសាហាវ ការរៀបចំទិវាជាតិក្នុងឆ្នាំនេះ ត្រូវបានប្តូរមកធ្វើក្នុងទម្រង់ជាយុទ្ធនាការតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងទូលំទូលាយទូទាំងប្រទេសទៅដល់សិស្សានុសិស្ស និស្សិត យុវជន មាតាបិតា អាណាព្យាបាល កម្មករនិយោជិត និយោជក និងសាធារណជនអំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅក្នុងការអភិវឌ្ឍជំនាញឱ្យកាន់តែមានគុណភាពនិងប្រសិទ្ធភាព សំដៅលើកកម្ពស់សមត្ថភាពរបស់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីចាប់យកឱកាសការងារកាន់តែល្អនិងលើកស្ទួយកម្រិតជីវភាពកាន់តែប្រសើរឡើង។

នៅក្នុងគ្រប់ដំណាក់កាលនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់ប្រទេស ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើរតួនាទីជាគន្លឹះក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយចំណេះដឹង ជំនាញ ព្រមទាំងឥរិយាបថការងារ និងសីលធម៌វិជ្ជាជីវៈល្អ ដែលជាមូលដ្ឋានចម្បងសម្រាប់ជំរុញល្បឿនកំណើនសេដ្ឋកិច្ច និងការបង្កើតការងារល្អសម្រាប់ប្រជាពលរដ្ឋ ដោយសារមូលធនមនុស្សគឺជាកត្តាកំណត់នៃផលិតភាពការងារ ការបង្កើតតម្លៃបន្ថែម សមត្ថភាពប្រកួតប្រជែង ភាពទាក់ទាញសម្រាប់ការវិនិយោគពីបរទេស និងការចាប់យកបច្ចេកវិទ្យាថ្មី។ ទន្ទឹមនឹងនេះ ជំនាញវិជ្ជាជីវៈក៏ចូលរួមចំណែកដ៏សំខាន់ក្នុងការបែងចែកផលលាភនៃកំណើន ប្រកបដោយសមធម៌និងបរិយាបន្ន ដោយដើរតួនាទីជាស្ពានចម្លងរវាងកំណើននិងការងារ ដោយហេតុថា ប្រសិនបើមិន

ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ និងការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ឆ្ពោះទៅសម្រេចបាននូវគោលដៅ *"យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"* សំដៅកសាងបាននូវកម្លាំងពលកម្មដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់ គំនិតច្នៃប្រឌិតនិងភាពប្រកួតប្រជែងខ្ពស់។ លើសពីនេះ ដើម្បីបង្កើតឱ្យមានភាពប្រទាក់ក្រឡាគ្នាកាន់តែមុតស្រួចស៊ីជម្រៅផ្នែកអាទិភាពគោលនយោបាយរវាងការបណ្តុះបណ្តាលលើកកម្ពស់ជំនាញវិជ្ជាជីវៈរបស់ប្រជាពលរដ្ឋនិងការកែប្រែរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិឈានទៅពឹងផ្អែកលើកំណើនផលិតភាព ព្រមទាំងការត្រៀមចាប់យកឱកាសនិងជម្នះផលវិបាកជាយថាហេតុពីបដិវត្តន៍ឧស្សាហកម្ម៤.០ សំដៅលើកស្ទួយភាពប្រកួតប្រជែង ទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់និងការបង្កើតការងារកាន់តែល្អ ដែលជាមូលដ្ឋានឆ្ពោះទៅសម្រេចក្តីប្រាថ្នាក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាលបានបូកបញ្ចូលរួមគ្នាទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នូវអាទិភាពនៃគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ គោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។

ការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលក្នុងការអនុវត្តឱ្យសម្រេចបានដោយជោគជ័យនូវចក្ខុវិស័យនិងគោលនយោបាយខាងលើ បានបង្ហាញឱ្យឃើញតាមរយៈការបង្កើនថវិកាជាតិយ៉ាងច្រើនជារៀងរាល់ឆ្នាំសម្រាប់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទន្ទឹមនឹងការកែទម្រង់ស៊ីជម្រៅជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់គុណភាពនិងពង្រីកលទ្ធភាពទទួលបានការបណ្តុះបណ្តាលសម្រាប់ប្រជាពលរដ្ឋគ្រប់រូបនៅទូទាំងប្រទេស។ ជាលទ្ធផល នាពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋអាចទទួលបានការបណ្តុះបណ្តាលជំនាញដោយងាយស្រួលនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈនិងឯកជន និងអង្គការ សមាគមនៅទូទាំងរាជធានី ខេត្ត ដោយកម្មវិធីបណ្តុះបណ្តាលត្រូវបានរៀបចំឱ្យមានភាពបត់បែនស្របតាមស្ថានភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងទម្រង់ជារយៈពេលខ្លីនិងវែង ទាំងក្នុងនិងក្រៅប្រព័ន្ធ ហើយអាចធ្វើឡើងនៅតាមគ្រឹះស្ថាន សហគ្រាស សហគមន៍ និងដោយចល័ត។ ដើម្បីផ្តល់លទ្ធភាពទទួលបានការបណ្តុះបណ្តាលប្រកបដោយសមធម៌ រាជរដ្ឋាភិបាលបានពង្រីកការផ្តល់អាហារូបករណ៍កាន់តែច្រើនឡើងសម្រាប់យុវជនដែលបានបោះបង់ចោលការសិក្សា ប្រជាពលរដ្ឋក្រីក្រ ស្ត្រី ជនពិការ កុមារកំព្រា ជនជាតិដើមភាគតិច ជនងាយរងគ្រោះ រួមទាំងកម្មករនិយោជិតដែលកំពុងត្រូវបានព្យួរការងារឬបាត់បង់ការងារដោយសារវិបត្តិជំងឺកូវីដ១៩។ លើសពីនេះទៀត ដើម្បីបន្តផ្តល់ការបណ្តុះបណ្តាលកុំឱ្យមានការអាក់ខាន និងប្រកបដោយសុវត្ថិភាពដល់សិស្សានុសិស្ស និស្សិត ក្នុងដំណាក់កាលដែលត្រូវអនុវត្តវិធានការសុខាភិបាលសំដៅទប់ស្កាត់កុំឱ្យជំងឺនេះរីករាលដាល រាជរដ្ឋាភិបាលបាននិងកំពុងអភិវឌ្ឍកម្មវិធីនិងធ្វើការបណ្តុះបណ្តាលជំនាញពីចម្ងាយតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន។ ទន្ទឹមនឹងនេះ ដើម្បីផ្តល់លទ្ធភាពងាយស្នាក់នៅរៀនសូត្រនិងបង្រៀន រាជរដ្ឋាភិបាលបានពង្រីកការកសាងជាបន្តបន្ទាប់នូវអន្តេវាសិកដ្ឋានសម្រាប់សិក្ខាកាម សិស្សានុសិស្ស និស្សិតក្រីក្រ និងស្ត្រីព្រមទាំងគ្រូ។ បន្ថែមលើនេះ បរិមាណគ្រូបច្ចេកទេសត្រូវបានបង្កើនជាបន្តបន្ទាប់តាមរយៈការធ្វើការជ្រើសរើសនិងបណ្តុះបណ្តាលថ្មីៗជារៀងរាល់ឆ្នាំ។ ជារួម ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានសិក្ខាកាម សិស្សានុសិស្សនិស្សិត និងកម្មករនិយោជិតជាង២០ម៉ឺននាក់ បានទទួលការបណ្តុះបណ្តាលជំនាញថ្មីនិងលើកកម្ពស់ជំនាញរបស់ខ្លួន ហើយបានចាប់យកឱកាសការងារល្អៗនិងបង្កើតមុខរបរដោយខ្លួនឯងដោយជោគជ័យ។

បន្ថែមលើការពង្រីកលទ្ធភាពទទួលបានការបណ្តុះបណ្តាល រាជរដ្ឋាភិបាលបានផ្តោតអាទិភាពខ្ពស់លើការលើកកម្ពស់គុណភាពឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនិងការប្រកួតប្រជែងទាំងក្នុងប្រទេសនិងជាមួយបណ្តាប្រទេសក្នុងតំបន់និងពិភពលោក ដោយពង្រីកការវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹង រួមមាន អគារសិក្សា រោងជាង បន្ទប់ពិសោធន៍ មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ មូលដ្ឋានសម្ភារៈនិងបរិក្ខារ និងទាំងផ្នែកទន់ រួមមាន ប្រព័ន្ធធានាគុណភាពនិងអភិបាលកិច្ច គុណភាព សមត្ថភាពគ្រូ ស្តង់ដាកម្មវិធីសិក្សា និងប្រព័ន្ធវាយតម្លៃផ្អែកលើសមត្ថភាព ទំនាក់ទំនងជាមួយផ្នែកឧស្សាហកម្ម និងការចុះកម្មសិក្សាអនុវត្តផ្ទាល់នៅកន្លែងធ្វើការ។ ជាមួយនឹងការខិតខំខាងលើ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈចំនួន២៣ ត្រូវបានទទួលស្គាល់គុណភាពពីអង្គការស្តង់ដាអន្តរជាតិ (ISO)។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការអនុវត្តប្រកបដោយជោគជ័យនូវគោលនយោបាយអាទិភាពនិងការកែទម្រង់ស៊ីជម្រៅដែលរាជរដ្ឋាភិបាលបានដាក់ចេញសម្រាប់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមអរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះសង្ឃគ្រប់ព្រះអង្គ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មាតាបិតា អាណាព្យាបាល អាជ្ញាធរដែនដី កម្មករនិយោជិត និយោជក ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងបងប្អូនជនរួមជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងនិងចំណាយធនធានសម្រាប់ជួយជ្រោមជ្រែងដល់ការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជា ព្រមទាំងបាននិងកំពុងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តរាល់វិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ដ៏កាចសាហាវ ប្រកបដោយស្មារតីទទួលខុសត្រូវ ស្រឡាញ់ជាតិមាតុភូមិ យកអាសាគ្នាក្នុងគ្រាលំបាក និងក្នុងស្មារតីជឿជាក់ថា ការរួមសាមគ្គីជាធ្លុងមួយនឹងអាចឱ្យកម្ពុជាជម្នះបាននូវបញ្ហាប្រឈមដ៏ធំនេះ ហើយនឹងរីកចម្រើនខ្លាំងជាងមុន និងមានអនាគតភ្លឺស្វាងបន្ទាប់ពីបញ្ហានេះបានឆ្លងផុត។

ជាថ្មីម្តងទៀត ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមយកឱកាសនេះ អំពាវនាវដល់ព្រះសង្ឃគ្រប់ព្រះអង្គ ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត មាតាបិតា អាណាព្យាបាល កម្មករនិយោជិត និយោជក ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងបងប្អូនជនរួមជាតិ ដូចតទៅ៖

១.បន្តចូលរួមទប់ស្កាត់កុំឱ្យរលកទី២នៃជំងឺកូវីដ១៩ដ៏កាចសាហាវនេះ ឆ្លងរីករាលដាលនៅតាមសហគមន៍ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ អន្តេវាសិកដ្ឋាន សហគ្រាស គ្រឹះស្ថាន កន្លែងស្នាក់នៅ និងក្នុងចំណោមសិស្សានុសិស្ស និស្សិត សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ កម្មករនិយោជិត និងនិយោជក ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការអនាម័យ សុខភាព និងសុវត្ថិភាពតាមការណែនាំរបស់ក្រសួងសុខាភិបាល ព្រមទាំងបន្តខិតខំផ្តល់ការបណ្តុះបណ្តាលតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយជៀសវាងការមើលស្រាលចំពោះស្ថានការណ៍បច្ចុប្បន្ន ដែលអាចនាំឱ្យកើតមានវិប្បដិសារីចំពោះខ្លួននិងក្រុមគ្រួសារជាទីស្រឡាញ់។

២.បន្តទាញយកផលឱ្យបានជាអតិបរមា ពីវិធានការអន្តរាគមន៍ផ្នែកសេដ្ឋកិច្ចសង្គមទាំងអស់របស់រាជរដ្ឋាភិបាល ដើម្បីរក្សាសកម្មភាពអាជីវកម្ម លើកស្ទួយកំណើន រក្សាការងារ បង្កើតការងារថ្មី លើកកម្ពស់សមត្ថភាពជំនាញ និងទ្រទ្រង់លំនឹងជីវភាពរបស់គ្រួសារកម្មករនិយោជិត។

៣.បន្តគាំទ្រអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីការអភិវឌ្ឍធនធានមនុស្សពោរពេញដោយសមត្ថភាពជំនាញ ដើម្បីធានាថា កម្លាំងពលកម្មរបស់បងប្អូនប្រជាពលរដ្ឋដែលអាចចាប់យកឱកាសការងារនិងលើកស្ទួយឱ្យសេដ្ឋកិច្ចជាតិអាចស្ទុះងើបឡើងវិញបានយ៉ាងរហ័សបន្ទាប់ពីវិបត្តិជំងឺកូវីដ១៩ ព្រមទាំងធានាថា កង្វះជំនាញនឹងមិនក្លាយជាឧបសគ្គធ្ងន់ធ្ងរដល់ការសម្រេចបាននូវកំណើនខ្ពស់និងអនាគតភ្លឺស្វាងក្នុងរយៈពេលមធ្យមនិងវែងខាងមុខ។

៤.បន្តជំរុញលើកទឹកចិត្តនិងបង្កើនការចុះឈ្មោះកូនចៅចូលរៀនជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីមានចំណេះដឹង ចំណេះធ្វើ ជំនាញច្បាស់លាស់ ឥរិយាបថការងារ និងសីលធម៌វិជ្ជាជីវៈល្អ ដែលជាកត្តាកំណត់ភាពប្រកួតប្រជែងសម្រាប់ចាប់យកឱកាសការងារល្អក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដែលនាំឱ្យគ្រួសារមានប្រាក់ចំណូលនិងជីវភាពកើនឡើង និងរួមចំណែកធ្វើឱ្យសេដ្ឋកិច្ចសង្គមមានការអភិវឌ្ឍ ដូចដែលប្រធានបទនៃទិវាជាតិនេះបានលើកឡើង "**TVET ធ្វើឱ្យជីវិតកាន់តែប្រសើរ**"។

៥.គ្រប់ស្ថានីយ៍វិទ្យុនិងទូរទស្សន៍របស់រដ្ឋនិងឯកជន ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយនានា សូមបន្តជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់លើវិស័យនេះ ក្នុងចំណោមសាធារណជន។

៦.ដោយឡែក ក្នុងឱកាសទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ លើកទី៣ ក្រោមប្រធានបទ "**TVET ធ្វើឱ្យជីវិតកាន់តែប្រសើរ**" នេះ សូមក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត មាតាបិតា អាណាព្យាបាល កម្មករនិយោជិត និយោជកផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងបងប្អូនជនរួមជាតិទាំងអស់ ចូលរួមសហការផ្សព្វផ្សាយទិវាជាតិនេះឱ្យបានផុលផុសឱឡារិកអធិកអធមទូទាំងប្រទេស។

ជាទីបញ្ចប់ ជាមួយនឹងឱកាសនៃការប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរនិងប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរចំពោះសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត និងបងប្អូនជនរួមជាតិទាំងអស់ទូទាំងប្រទេស សូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ** និង **ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២០

**ហ៊ុន សែន**